# គំនិត និង កិរិយា

សកម្មភាព វាមានវត្ថុធាតុគោលពីរយ៉ាងគឺ គំនិត និង កិរិយា របស់អ្នកធ្វើសកម្មភាព។ ឧបមា អ្នកធ្វើ គាត់មានគំនិតល្អប្រពៃ តែមានកិរិយាក្រអឺតក្រអោង វានឹងនាំអោយមានលទ្ធផល ជាភាពអន់បំផុត។ មួយវិញទៀតបើ អ្នកធ្វើ គាត់មានគំនិតអន់ តែគាត់មានកិរិយាល្អប្រពៃ វាក៏នឹងនាំអោយមានលទ្ធផល ជាភាពអន់នោះដែរ។ ដូច្នេះ បើចង់អោយមានលទ្ធផល មានភាពប្រសើរ លុះត្រាតែ គំនិត និង កិរិយា វាមានភាពថ្លៃថ្លាដូចគ្នា។ ជាឧទាហរណ៍ : ជនផ្តាច់ការ ឬ អ្នកបាត តែងតែយកគំនិតល្អមកបញ្ឆោត, រីឯ អ្នកប្រាជ្ញក្លែងក្លាយ ឬ អ្នកល្ងង់វិញ ច្រើនយកគំនិតកញ្ឆោតមកអនុវត្ត, ទង្វើនេះ វានាំបង្កើតនូវលទ្ធផលដូចគ្នាដោយជាក់គឺ អប្បបញ្ញា។ ដូច្នេះ លទ្ធផល នៃសកម្មភាព គឺការរៀបចំ គំនិត និង កិរិយា ដែលបានអនុវត្ត, ដោយហេតុនេះ គេទុកទីបញ្ចប់ ជាអ្វីៗទាំងអស់ ឬ ជារបស់ដែលសំខាន់ជាងគេបង្អស់របស់សកម្មភាព។ សួរថា ចុះបើលទ្ធផល វាមានភាពគម្រក់ក្រៃពេក តើគេអាចទុកអ្នកប្រព្រឹត្ត ជាជនបែបណា ? តើរឿងនេះ គេអាចប្រដូចនឹងសកម្មភាពរបស់ពួកនយៈជន (អ្នកនយោបាយ) ខ្មែរ បានដែរឬទេ ? មានអ្នកប្រាជ្ញ ជាអ្នកប្រឆាំង និង ជនផ្តាច់ការ នាំគ្នាធ្វើសកម្មភាពអស់រយៈពេលដ៏យូរអង្វែង តែលទ្ធផលបូកបោះទៅគឺ នាំគ្នារចនាស្រុកខ្មែរ ឲទៅជានគរខ្ញុំ យួន-ចិន។ តើនៅត្រង់ចំណុចណា ដែលហៅថា មោទនភាព ជាខ្មែរ ?